ទំរង់រដ្ឋបាល និងឯកឧត្តម អស់លោកដែលមានឈ្មោះក្នុងប្រការ២ ត្រូវអនុវត្តសេចក្តីសំរេច នេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

ជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

ប្រធាន

សុខ អាន

★★★

រាជធានីភ្នំពេញ ថ្ងៃទី ៣១ នៃសីហា ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ៦១ សសរ.

## ស្តីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាល

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ នៃវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ នៃកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

**ប្រការ ១ :** ផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទីនៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅក្រៅប្រទេស ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៩ រហូតដល់សម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សាការដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

# III- ក្រុមប្រឹក្សាធម្មនុញ្ញ

## សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៩

**សេចក្តីសំរេចលេខ ១៣ គមធ.សសរ.ច**

***

**ក្រុមប្រឹក្សាធម្មនុញ្ញ**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ចស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា ធម្មនុញ្ញ
- បានឃើញ សំណើសុំឲ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ស្តីពីរយៈពេលនៃការឃុំខ្លួនជាបណ្តោះអាសន្ន ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩ របស់ក្រុមអ្នកតំណាងរាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលបាននៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៩

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- ដោយឃើញថា ពាក្យបណ្តឹងរបស់អ្នកតំណាងរាស្ត្រចំនួន១៣រូប ធ្វើបានត្រឹមត្រូវតាមបែបបទច្បាប់ប៉ុន្តែខុសនឹងគតិច្បាប់
- ដោយឃើញថា ព្រះរាជាណាចក្រកម្ពុជា បានប្រកាសសច្ចាប្រណិធាន ស្តីពីការបង្ការ និងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី១៩